# ៩.ព្រេងទាក់ទងនឹងទំនៀមដាក់ផ្កា និងទៀន-ធូបក្នុងដៃខ្មោច

---

មានរឿងដំណាលថា :

កាលពីមុន មានភិក្ខុមួយរូប មានឈ្មោះមិនប្រាកដ ។ ញោមប្រុសរបស់លោកជាមេព្រៃសម្លាប់សត្វច្រើនណាស់ តាំងពីក្មេងដល់ចាស់ ។ លុះវេលាជិតនឹងស្លាប់ គាត់ភ្លឹកស្មារតីទៅឃើញសត្វដែលខ្លួនបានសម្លាប់ដោយអកុសលចិត្ត ក៏ស្រែកប្រាប់ឲ្យភិក្ខុជាកូនជួយ ។ ភិក្ខុជាកូនដឹងថា "ញោមមានកម្មច្រើន បានជាភ្លឹកទៅឃើញតែសត្វធាតុដូច្នេះ" ទើបចាត់មនុស្សឲ្យរកផ្កា ទៀន និង ធូប យកមកដាក់ក្នុងដៃញោមប្រុស រួចប្រាប់ថា "ចូរញោមខំសម្លឹងមើលផ្កា ទៀន និង ធូប ជាគ្រឿងបូជាព្រះរតនត្រ័យនេះ ឲ្យជាប់" ។ ញោមប្រុសនៃភិក្ខុនោះ កើតសទ្ធាជ្រះថ្លា មានចិត្តជាកុសល ក៏ធ្វើតាមពាក្យកូន ។ លុះដល់ស្លាប់ទៅ គាត់ក៏បានទៅកើតនៅនាស្ថានសួគ៌ ។

ព្រោះហេតុនេះ បានជាមនុស្សជាន់ក្រោយធ្វើតាមតៗ គ្នាមក ដោយប្រាថ្នាឲ្យអ្នកជំងឺយកគុណព្រះរតនត្រ័យជាទីពឹង ។

រឿងនេះ ក៏ជាប់ជាទំនៀមរហូតមក ។